# មជ្ឈមណ្ឌលភីឌីភី
# PDP-CENTER

## គោលការណ៍
## ស្តីពី
## ការជ្រើសរើសបុគ្គលិករបស់មជ្ឈមណ្ឌលភីឌីភី

ដើម្បីអោយមានយុត្តិធម៌ និង តម្លាភាព ក្នុងការជ្រើសរើសបុគ្គលិក មជ្ឈមណ្ឌលភីឌីភីសំរេចដាក់ចេញនូវគោលការណ៍ដូចខាងក្រោម:

**I. ការទទួលខុសត្រូវក្នុងការជ្រើសរើសបុគ្គលិក :**

ផ្នែករដ្ឋបាលនៃមជ្ឈមណ្ឌលភីឌីភី គឺជាអ្នកទទួលខុសត្រូវក្នុងការរៀបចំដំណើរការនៃការជ្រើសរើសបុគ្គលិកនេះ ។

**II. ប្រភពនៃការជ្រើសរើស :** ប្រភពការជ្រើសរើសមានពីរ:

**ក. ខាងក្នុង :** ការជ្រើសរើសនៅក្នុងករណីនេះគឺពិនិត្យមើលទៅលើសមត្ថភាពរបស់ បុគ្គលិក បុគ្គលិកស្ម័គ្រចិត្ត សមាជិកដែលសកម្មនឹងការងារ ឬជាអតីតបុគ្គលិកនៅក្នុងអង្គការដែលធ្លាប់បំរើការងារកន្លងមក ។

**ខ. ខាងក្រៅ :** យុវជនកម្ពុជា ឬប្រជាពលរដ្ឋមកពីមជ្ឈដ្ឋាននានាក្នុងព្រះរាជាណាចក្រកម្ពុជា ។

**III. របៀបជ្រើសរើស**

**១. លក្ខណៈវិនិច្ឆ័យសំខាន់ៗ :**

- ជនដែលមានការប្តេជ្ញាចិត្តខ្ពស់ មានសក្តានុពលខ្លាំងក្លានិងតស៊ូមោះមុតក្នុងការធ្វើការងារលើគោលនយោបាយគ្រឿងស្រវឹង ការប្រឆាំងអំពើពុករលួយ និង ការលើកកំពស់ប្រជាធិបតេយ្យ ។
- មានចំណេះដឹងជាមូលដ្ឋានពាក់ព័ន្ធនឹងកម្មវិធី
- បើមានបទពិសោធន៍ពាក់ព័ន្ធដទៃទៀតក៏ជាប្រការដ៏ប្រសើរដែរ ។

**២. មុនពេលសំភាសន៍ :**

**ក-ផ្សព្វផ្សាយអោយបេក្ខជនដាក់ពាក្យ ៖** ត្រូវផ្សព្វផ្សាយជាសាធារណៈ អោយមានការដាក់ពាក្យប្រកួតប្រជែងដោយស្មើភាព។

- ការផ្សព្វផ្សាយត្រូវបិទនៅមុខទីស្នាក់ការមជ្ឈមណ្ឌលភីឌីភី ផ្សាយតាមវិទ្យុ ទូរទស្សន៍ វី សារពត៌មានផ្សេងៗ តែការផ្សព្វផ្សាយនេះនឹងធ្វើទៅតាមកំរិតធនធានរបស់អង្គការ ។

**ខ-ការដាក់ពាក្យសុំ:** ការដាក់ពាក្យសុំជាបេក្ខជនត្រូវអនុវត្តដូចខាងក្រោម:

-បំពេញពាក្យសុំ (បើមានទំរង់ស្រាប់) មួយច្បាប់ ។

-សរសេរលិខិតផ្ទាល់ខ្លួន (**Cover Letter**) មួយច្បាប់ ។

-សរសេរ **C.V** ដោយ បញ្ជាក់សំខាន់ពី ឈ្មោះ អាស័យដ្ឋាន/ទូរស័ព្ទទំនាក់ទំនង កំរិតវប្បធម៌ បទពិសោធន៍ការងារ វគ្គបណ្តុះបណ្តាលខ្លីៗដែលបានឆ្លងកាត់ ព្រមទាំងអ្នកធានាពីរនាក់ ដោយមានដាក់អាស័យដ្ឋាន និងលេខទូស័ព្ទទំនាក់ទំនងផងដែរ ។

**គ-ការជំរុះ** **(Sort List)** : ការជំរុះត្រូវធ្វើឡើងមុនពេលឈានចូលដល់ការសំភាសន៍ផ្លូវការ។ ការសំភាសន៍ផ្លូវការ នឹងត្រូវធ្វើឡើងយ៉ាងយូរមួយសប្តាហ៍បន្ទាប់ពីប្រកាសលទ្ធផលនៃការជំរុះ **(Sort List)** ។

**៣. ការសំភាសន៍ :** ការសំភាសន៍នឹងផ្តោតទៅលើ:

**-អាការៈខាងក្រៅ:** អាការៈខាងក្រៅនឹងពិនិត្យមើលទៅលើអាកប្បកិរិយា អត្តចរិក ឥរិយាបថ និង ការសំដែងចេញមកខាងក្រៅរបស់បេក្ខជន ។

**-ចំណេះដឹងផ្នែកការងារ:** សួរសំណួរពាក់ព័ន្ធនឹងចំណេះដឹងជាមូលដ្ឋាន ជាមួយការងារដែលពួកគេនឹងត្រូវអនុវត្ត។

**-ការធ្វើការងារជាក់ស្តែង:** ត្រូវអោយអ្នកដាក់ពាក្យសុំធ្វើការងារ ធ្វើការសាកល្បងបង្រៀន ឬធ្វើការងារដែលពាក់ព័ន្ធនឹងការងារដែលនឹងត្រូវអនុវត្ត ។

**៤- ការធ្វើសេចក្តីសំរេចចិត្ត**

**ក-គណៈកម្មការជ្រើសរើស:**

- ត្រូវមានគណៈកម្មការជ្រើសរើសមួយដែលមានសមាជិកយ៉ាងតិចបីរូប។ គណៈកម្មការនេះត្រូវបង្កើតឡើងដោយគណៈកម្មាធិការប្រតិបត្តិ ។ គណៈកម្មការជ្រើសរើសនេះត្រូវស្ថិតក្រោមការដឹកនាំរបស់ ផ្នែករដ្ឋបាលទីស្នាក់ការកណ្តាល។

- ក្នុងករណីជ្រើសរើសនៅតាមបណ្តាខេត្ត-ក្រុងត្រូវអោយប្រធានសាខា និង អ្នកពាក់ព័ន្ធនឹងគំរោងចូលរួមផងដែរ ។

-សមាសភាពគណកម្មការជ្រើសរើសត្រូវមានសមាសភាពបុរស និង ស្ត្រីចូលរួមជាចាំបាច់។

-គណកម្មាធិការជ្រើសរើស ត្រូវជ្រើសរើសយកអ្នកដែលមានសមត្ថភាពយ៉ាងតិចពីររូបក្នុងមួយមុខតំណែង ដើម្បីដាក់ជូនគណកម្មាធិការប្រតិបត្តិ (Management Team) សំរេចជាចុងក្រោយ ។

**ខ-គណកម្មការប្រតិបត្តិ** : ការសំរេចចិត្តរបស់គណកម្មាធិការប្រតិបត្តិគឺ ផ្អែកលើរបាយការណ៍ប្រធានគណកម្មកាជ្រើសរើស និង សុភវិនិច្ឆ័យផ្ទាល់ខ្លួនរបស់សមាជិកគណកម្មាធិការប្រតិបត្តិម្នាក់ៗ និង ពតិមានផ្សេងៗដែលខ្លួនទទួលបាន។ ការសំរេចចិត្តរបស់គណកម្មាធិការប្រតិបត្តិគឺធ្វើឡើងតែចំពោះបុគ្គលិកណាដែលមិនមែនជាប្របធានមជ្ឈមណ្ឌលភីឌីភី។ ចំពោះប្រធានបោះឆ្នោតជ្រើសតាំងដោយមហាសន្និបាតរៀងរាល់បួនឆ្នាំម្តង ។

**៥. ការសាកសួរទៅអ្នកធានា :**

ក្រោយពេលសំភាសន៏ចប់អង្គការនឹងធ្វើការសាកសួរតាមរយៈទូរសព្ទ័ទៅកាន់អ្នកធានារបស់ពួកគេដើម្បីទទួលបានពតិមានបន្ថែមពាក់ពន្ទ័នឹងអត្តចរិក និង ពតិមានមួយចំនួនរបស់អ្នកដាក់ពាក្យសុំធ្វើការងារដែលបានសរសេរនៅក្នុង C.V របស់ពួកគេយ៉ាងតិចចំនួនពីរនាក់។

**៦. ការទទួលយក ឬបដិសេធបេក្ខជន :**

បើសិនជាអង្គការសំរេចជ្រើសរើសបុគ្គលិកនោះ រឺមិនយកគឺត្រូវជូនដំណឹងដល់សាម៉ីខ្លួនជ្រាបយ៉ាងយូរមួយសប្តាហ៍បន្ទាប់ពីថ្ងៃប្រជុំសំរេច។ បុគ្គលដែលអង្គការសំរេចជ្រើសរើសយកអោយធ្វើជាបុគ្គលិកត្រូវធ្វើសាកល្បងការងាររយៈពេលបីខែ ។ បន្ទាប់ពីសាកល្បងការងារបានជោគជ័យហើយអង្គការនឹងផ្តល់កុងត្រាស្របតាមរយៈពេលនៃកម្មវិធីនីមួយៗ ដែលបានចុះកិច្ចសន្យាជាមួយម្ចាស់ជំនួយ ។តែកុងត្រាត្រូវសើររើរៀងរាល់មួយឆ្នាំម្តង។

## VI. **ការតំរង់ទិសការងារ** (orientation)

រដ្ឋបាលនៃមជ្ឈមណ្ឌលភីឌីភីត្រូវទទួលខុសត្រូវក្នុងការរៀបចំធ្វើការតំរង់ទិសនេះ ពាក់ព័ន្ធនឹងការងារដែលត្រូវអនុវត្តនិង អង្គការទាំងមូល ។ការតំរង់ទិសនេះត្រូវរៀបចំអោយបុគ្គលិកថ្មីបានជួបជាមួយផ្នែកពាក់ព័ន្ធនានាផងដែរ។

គោលការណ៍នេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

គោលការណ៍នេះអនុម័តនៅថ្ងៃទី ២០ ខែ កុម្ភះ ឆ្នាំ២០០៦

**មជ្ឈមណ្ឌលភីឌីភី**

**ប្រធាន**

**យ៉ង់ គិមអេង**